# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍
### អគ្គនាយកដ្ឋានទឹកស្អាត

# គោលការណ៍ណែនាំ
# ស្តីពី
# ការចុះធ្វើអធិការកិច្ចបច្ចេកទេសប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

Guideline on Technical Site Inspection for Water Supply System

**រៀបចំដោយ ៖ នាយកដ្ឋានបច្ចេកទេសនិងគ្រប់គ្រងគម្រោង**
**សហការដោយ ៖ គម្រោងពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យទឹកស្អាតទីប្រជុំជនកម្ពុជា**

**ខែមីនា ឆ្នាំ២០២៣**

# មាតិកា


១. សេចក្តីផ្តើម ........ 1

១.១. សាវតា ........ 1

១.២. គោលបំណង ........ 1

១.៣. វិសាលភាព ........ 1

២. ជំហានទាក់ទងនឹងការងារអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ........ 1

២.១. ការដាក់លិខិតស្នើសុំ/ស្នើសុំបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ... 2

២.២. ការប្រមូលទិន្នន័យបឋម ........ 2

២.៣. មន្ត្រីអធិការកិច្ច ........ 3

*២.៣.១. សមាជិកក្រុមមន្ត្រីអធិការកិច្ច ........ 3*

*២.៣.២. ការកំណត់ក្រុមមន្ត្រីអធិការកិច្ច ........ 4*

*២.៣.៣. ប្រធានក្រុមមន្ត្រីអធិការកិច្ច ........ 4*

២.៤. ការធ្វើអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ........ 5

២.៥. ការធ្វើរបាយការណ៍ស្នើសុំចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ... 6

*២.៥.១. របាយការណ៍ស្នើសុំចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត6*

*២.៥.២. ការប្រជុំត្រួតពិនិត្យ និងវាយតម្លៃ (របាយការណ៍របស់មន្ទីររាជធានី-ខេត្ត) 7*

*២.៥.៣. ការចេញ-ទទួលបានវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត.....7*

៣. ការសិក្សាលើលក្ខណៈបច្ចេកទេស ........ 7

៣.១. ការគណនាតម្រូវការទឹក ........ 7

៣.២. ការគណនាទឹកបាត់បង់ ........ 8

៣.៣. ការគណនាការប្រើប្រាស់ថាមពលអគ្គិសនី ........ 8

៣.៤. ការដាក់បញ្ចូលសារធាតុផ្គុំកករ និងសារធាតុសម្លាប់មេរោគ ........ 9

៣.៥. ការសិក្សាលក្ខណៈប្រភពទឹក........ 9

៣.៦. ការសិក្សាអំពីស្ថានភាពស្ថានីយបូមទឹកឆៅ........ 10

៣.៧. ការសិក្សាអំពីដំណើរប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត (Conventional) .................... 14
៣.៨. ការសិក្សាលើប្រព័ន្ធចែកចាយទឹកស្អាត .................................................. 22
៣.៩. ការតាមដានគុណភាពទឹកស្អាត.................................................................. 23
៤. ការផ្ដល់អនុសាសន៍លើលក្ខណៈបច្ចេកទេស.................................................24
៤.១. ការបរាជ័យលើការផ្ដុំកករ ....................................................................... 24
៤.២. ការបរាជ័យលើការរងកករ ..................................................................... 25
៤.៣. ការបរាជ័យលើការច្រោះ ....................................................................... 26
៥. ការសិក្សា ..................................................................................................28
៦. ឧបសម្ព័ន្ធ...................................................................................................31

## ១. សេចក្តីផ្តើម

### ១.១. សាវតា

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាក្រសួងដែលទទួលបន្ទុកដឹកនាំ និងគ្រប់គ្រងវិស័យទឹកស្អាតទីប្រជុំជនទូទាំងប្រទេស។ បច្ចុប្បន្នមានរដ្ឋាករទឹកស្វយ័តចំនួន ២, អង្គភាពរដ្ឋាករទឹកសាធារណៈចំនួន១០ (ដែលមានទីតាំងនៅរាជធានីចំនួន១, ទីរួមខេត្តចំនួន ៩ និងទីប្រជុំជនស្រុក ចំនួន២) និងប្រតិបត្តិករទឹកស្អាតចំនួន ៣៦៥ ដែលទទួលបានការអនុញ្ញាតឱ្យធ្វើការផ្គត់ផ្គង់ទឹកស្អាត ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ដើម្បីឱ្យដំណើរការអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតស្របតាមនីតិវិធី និងបទដ្ឋានគតិយុត្តិរបស់ក្រសួង ប្រតិបត្តិករទឹកស្អាតទាំងអស់ត្រូវតែមានការអនុញ្ញាតពីក្រសួងនូវឯកសារចំនួន ២ គឺ (១) ប្រកាសស្តីពីការផ្តល់ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និង (២) វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត។ វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត មានសុពលភាព ៥ (ប្រាំ)ឆ្នាំ និងត្រូវស្នើសុំបន្តសុពលភាពរៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង។

### ១.២. គោលបំណង

គោលការណ៍ណែនាំនេះ ផ្តល់នូវចំណេះដឹងជាមូលដ្ឋានសម្រាប់មន្ត្រីអធិការកិច្ចរបស់អគ្គនាយកដ្ឋានទឹកស្អាត និងមន្ត្រីអធិការរបស់មន្ទីររាជធានី-ខេត្ត សម្រាប់ការងារចុះអធិការកិច្ចលើលក្ខណៈបច្ចេកទេសនៃប្រព័ន្ធផ្គត់ផ្គត់ទឹកស្អាត។

### ១.៣. វិសាលភាព

គោលការណ៍ណែនាំនេះ មានវិសាលភាពគ្របដណ្តប់ការងារអធិការកិច្ចលើលក្ខណៈបច្ចេកទេសប្រព័ន្ធផ្គត់ផ្គត់ទឹកស្អាតរបស់ប្រតិបត្តិករទឹកស្អាតទូទាំងប្រទេស ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាពិសេសសម្រាប់ប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតប្រភេទ Conventional។

## ២. ជំហានទាក់ទងនឹងការងារអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

ការងារអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត មានចំនួន ៦ (ប្រាំមួយ) ជំហានសំខាន់ៗ រួមមាន៖ ១) ការដាក់ពាក្យស្នើសុំ/ស្នើសុំបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត, ២) ការប្រមូលទិន្នន័យបឋម, ៣) ការរៀបចំក្រុមមន្ត្រីអធិការកិច្ច, ៤) ការធ្វើអធិការកិច្ច, ៥) ការធ្វើរបាយការណ៍ស្នើសុំចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត និង ៦) ការចេញ-បន្ត

វិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត។ ដ្យាក្រាមខាងក្រោមបង្ហាញពីជំហានទាក់ទងនឹងការងារអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។




រូបភាពទី១៖ ជំហានទាក់ទងនឹងការងារអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

## ២.១. ការដាក់លិខិតស្នើសុំ/ស្នើសុំបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

ប្រតិបត្តិករទឹកស្អាតទាំងអស់ត្រូវដាក់លិខិតស្នើសុំ/ស្នើសុំបន្តវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ មន្ត្រីអធិការកិច្ចរបស់ក្រសួង ឬ មន្ទីររាជធានី-ខេត្ត ត្រូវចុះធ្វើអធិការកិច្ចបច្ចេកទេសលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដែលបានដាក់ពាក្យស្នើសុំ ក្នុងរយៈពេលជាក់លាក់មួយទៅតាមការកំណត់របស់ក្រសួង។ ពេលវេលាដែលប្រតិបត្តិករទឹកស្អាតត្រូវដាក់ពាក្យស្នើសុំគឺ៖

១) ដំណើរការសាកល្បងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្រោយពីបញ្ចប់ការសាងសង់

២) ៩០ (កៅសិប)ថ្ងៃមុនពេលវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតបច្ចុប្បន្នអស់សុពលភាព។

## ២.២. ការប្រមូលទិន្នន័យបឋម

ជំហាននេះ គឺជាការសិក្សាបឋមទៅលើការដំណើរការនៃការផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករ បន្ទាប់ពីប្រតិបត្តិករដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ផ្អែកលើទិន្នន័យដែលបានមកពីប្រព័ន្ធគ្រប់គ្រងការចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

(COSM) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យសេវាផ្គត់ផ្គង់ទឹកស្អាត (WSMS) និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលអគ្គនាយកដ្ឋានទឹកស្អាតមាន ដើម្បីជាមូលដ្ឋានដល់ក្រសួងក្នុងការចាត់តាំង និងរៀបចំក្រុមមន្ត្រីអធិការកិច្ចរបស់អគ្គនាយកដ្ឋានទឹកស្អាត ឬ មន្ទីរ ក្នុងការចុះអធិការកិច្ច។

ក្នុងករណី ក្រុមមន្ត្រីអធិការកិច្ចរបស់អគ្គនាយកដ្ឋានទឹកស្អាតត្រូវបានចាត់តាំង, មន្ត្រីអធិការកិច្ចត្រូវរៀបចំ ប្រមូលព័ត៌មានទាក់ទងនឹងស្ថានភាព ការដំណើរការ និងគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករ ដូចជា៖

- របាយការណ៍សិក្សាសមិទ្ធិលទ្ធភាព
- ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- ផែនការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ប្លង់បច្ចេកទេសប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ដំណើរការនៃប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត
- ទិន្នន័យនៃការប្រតិបត្តិការបច្ចុប្បន្ន (ឯកសារនេះត្រូវស្នើសុំពីប្រតិបត្តិករយ៉ាងតិចមួយសប្តាហ៍ជាមុន)
- និងទិន្នន័យចាំបាច់ផ្សេងៗទៀត

## ២.៣. មន្ត្រីអធិការកិច្ច

### *២.៣.១. សមាជិកក្រុមមន្ត្រីអធិការកិច្ច*

ដើម្បីចុះអធិការកិច្ចបច្ចេកទេសលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករទឹកស្អាតប្រកបដោយប្រសិទ្ធភាព សមាសភាពមន្ត្រីអធិការកិច្ចរបស់អគ្គនាយកដ្ឋានទឹកស្អាត ឬ មន្ទីររាជធានី-ខេត្ត យ៉ាងហោចណាស់មានចំនួន ៣ (បី) រូប ដែលត្រូវអនុវត្តលើការងារផ្សេងៗគ្នា ក្នុងកំឡុងពេលចុះអធិការកិច្ច ក្នុងនោះ មន្ត្រី ១ រូប ជាប្រធានក្រុមមន្ត្រីអធិការកិច្ច។ ភារកិច្ចរបស់សមាជិកមន្ត្រីអធិការកិច្ច មានដូចក្នុងតារាងទី១ ខាងក្រោម។

តារាងទី១៖ ភារកិច្ចរបស់សមាជិកមន្ត្រីអធិការកិច្ច

| ពិពណ៌នា | ភារកិច្ច | ចំនួនមន្ត្រី |
|---|---|---|
| ដំណើរការប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត | ពិនិត្យ និងផ្តល់ការណែនាំទៅលើលក្ខណៈបច្ចេកទេសនៃហេដ្ឋារចនាសម្ព័ន្ធរបស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត និងដំណើរការប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត | ១ រូប |

| | | |
|---|---|---|
| បរិក្ខារ (អគ្គិសនី និងមេកានិក) | ពិនិត្យ និងផ្តល់ការណែនាំទៅលើស្ថានភាពនៃការតំឡើង ស្ថានភាពដំណើរការ និងការថែទាំបរិក្ខារអគ្គិសនី និងមេកានិក | ១ រូប |
| គុណភាពទឹក និងការចែកចាយទឹក | ពិនិត្យគុណភាពទឹក, ការចែកចាយទឹក និងផ្តល់ការណែនាំបច្ចេកទេសក្នុងការរក្សាគុណភាពទឹក និងការចែកចាយទឹកក្នុងន័យធ្វើឱ្យប្រសើរឡើងនូវគុណភាពទឹក និងការចែកចាយទឹកជូនអតិថិជន | ១ រូប |
| ទីប្រឹក្សា (បើសិនមាន) | ការចូលរួមពីទីប្រឹក្សាបើសិនជាចាំបាច់ | |

### *២.៣.២. ការកំណត់ក្រុមមន្ត្រីអធិការកិច្ច*

ក្រោយពេលដែលក្រសួងបានទទួលលិខិតស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតពីប្រតិបត្តិករ ក្នុងរយៈពេលជាក់លាក់មួយទៅតាមការកំណត់ដោយក្រសួង, ក្រសួងមានសិទ្ធិក្នុងការសម្រេច និងចាត់តាំងក្រុមអធិការកិច្ច ដើម្បីចុះធ្វើអធិការកិច្ចបច្ចេកទេសលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករ ដែលអាចជាក្រុមមន្ត្រីអធិការកិច្ចរបស់អគ្គនាយកដ្ឋានទឹកស្អាត និង ឬ ក្រុមមន្ត្រីអធិការកិច្ចរបស់មន្ទីររាជធានី-ខេត្ត។

ករណី ការធ្វើអធិការកិច្ចត្រូវអនុវត្តដោយក្រុមមន្ត្រីអធិការកិច្ចរបស់អគ្គនាយកដ្ឋានទឹកស្អាត គឺត្រូវស្នើសុំការអនុញ្ញាតពីថ្នាក់ដឹកនាំ ដោយមានកាលបរិច្ឆេទចុះធ្វើអធិការកិច្ចច្បាស់លាស់។ មន្ត្រីអធិការកិច្ចរបស់អគ្គនាយកដ្ឋានទឹកស្អាត ក៏ត្រូវជូនដំណឹងដល់មន្ទីររាជធានី-ខេត្ត ពីកម្មវិធីចុះអធិការកិច្ច និងផ្ញើឯកសារ (កម្រងសំនួរ) សម្រាប់ប្រតិបត្តិករបំពេញទិន្នន័យទុកជាមុនបម្រើដល់ការចុះធ្វើអធិការកិច្ច ដើម្បីមន្ទីរបន្តជូនដំណឹង និងសម្របសម្រួលជាមួយប្រតិបត្តិករ។

### *២.៣.៣. ប្រធានក្រុមមន្ត្រីអធិការកិច្ច*

ប្រធានក្រុមមន្ត្រីអធិការកិច្ចបច្ចេកទេសលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត មានតួនាទីក្នុងការដឹកនាំ និងសម្របសម្រួលក្នុងការធ្វើអធិការកិច្ច រួមទាំងការវិភាគទិន្នន័យ ការសម្ភាសន៍ ការវាយតម្លៃ និងការសន្និដ្ឋានលទ្ធផលនៃការធ្វើអធិការកិច្ច។ ក្រោយពីចុះអធិការកិច្ច ប្រធានក្រុមត្រូវចុះហត្ថលេខាលើកំណត់ត្រាជាមួយប្រតិបត្តិករ ឬ តំណាង និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំអំពីលទ្ធផលនៃការធ្វើអធិការកិច្ច និងគោរពស្នើសុំការចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតជូនប្រតិបត្តិករ ឬ ត្រូវតាមដានវឌ្ឍនភាពនៃការកែលំអរតាមអនុសាសន៍របស់ក្រុមអធិការកិច្ចមុននឹងអាចចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ជូនប្រតិបត្តិករបាន។

## ២.៤. ការធ្វើអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

- *បញ្ជាក់ពីស្ថានភាពនៅចុងបណ្តាញ*

មន្ត្រីអធិការកិច្ចនិងប្រតិបត្តិករ ត្រូវចុះទៅជួបអតិថិជនដែលរស់នៅក្នុងតំបន់សេវាកម្ម ដែលស្ថិតនៅឆ្ងាយពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (សន្មត់ថាចុងបណ្តាញ) ដើម្បីធ្វើការត្រួតពិនិត្យសម្ពាធទឹក និងគុណភាពទឹកនៅតាមផ្ទះរបស់អតិថិជន និងសាកសួរអំពីព័ត៌មានមួយចំនួនទាក់ទងនឹងសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករ។ ឧ. "តើពួកគេអាចប្រើប្រាស់ទឹកនៅពេលដែលត្រូវការ និងតាមបរិមាណដែលពួកគេត្រូវការដែរទេ? តើទឹកតែងតែស្អាតដែរឬទេ? តើទឹកធ្លាប់មានក្លិនឬការបំពុលដែរឬទេ? ព័ត៌មានដែលទទួលបានទាំងនេះ សម្រាប់ធ្វើជាមូលដ្ឋានបន្ថែមទៀតដល់មន្ត្រីអធិការកិច្ច ក្នុងអំឡុងពេលត្រួតពិនិត្យប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត។

ជាធម្មតា សម្ពាធទឹកចែកចាយប្រែប្រួលទៅតាមសណ្ឋានដីនៃតំបន់សេវាកម្មរបស់ប្រតិបត្តិករនីមួយៗ ហើយសម្ពាធតែងតែខ្សោយនៅផ្នែកណាមួយនៃតំបន់សេវាកម្មដែលមានរយៈកំពស់ខ្ពស់ជាងគេ។ ដូចនេះ ប្រតិបត្តិករចាំបាច់ត្រូវធ្វើការតាមដាន និងត្រួតពិនិត្យសម្ពាធនៅតំបន់សេវាកម្មដែលមានរយៈកំពស់ខ្ពស់ ក៏ដូចជាតាមដាននៅចុងបណ្តាញផងដែរ។

- *ការវិភាគទិន្នន័យ និងការសម្ភាសន៍ជាមួយប្រតិបត្តិករ ឬ បុគ្គលិក*

មន្ត្រីអធិការកិច្ចត្រូវបញ្ជាក់ជាមួយប្រតិបត្តិករថា តើបានរក្សាទុកឯកសារចាំបាច់ទាក់ទងនឹងដំណើរការប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងបានយល់ពីកម្រងសំនួរដែលមន្ត្រីអធិការកិច្ចឱ្យបំពេញទុកជាមុនដែរឬទេ? មន្ត្រីអធិការកិច្ចត្រូវពន្យល់ដល់ប្រតិបត្តិករឱ្យយល់ច្បាស់លាស់ អំពីកម្រងសំណួរ ឬ តារាងទិន្នន័យដែលប្រតិបត្តិករត្រូវបំពេញ តាមការចាំបាច់។

មន្ត្រីអធិការកិច្ចនឹងវិភាគទិន្នន័យដោយប្រើប្រាស់តារាង Checklist (ឧបសម្ព័ន្ធទី២) និងដោយផ្អែកលើកម្រងសំនួរ និងការសម្ភាសន៍បន្ថែមតាមការចាំបាច់។ ការវិភាគទិន្នន័យ គឺជាការចាំបាច់ដើម្បីបញ្ជាក់ថា ទិន្នន័យដែលប្រតិបត្តិកររាយការណ៍សមស្រប និងអាចទទួលយកបានឬទេ? ការវិភាគទិន្នន័យ ក៏ជួយដល់មន្ត្រីអធិការកិច្ចស្វែងយល់អំពីបញ្ហាប្រឈម ឬ ចំណុចខ្វះខាតនៃដំណើរការអាជីវកម្មរបស់ប្រតិបត្តិករ ផងដែរ។

- *ការធ្វើអធិការកិច្ចជាក់ស្តែង (ការថែទាំ/គុណភាពទឹក)*

ដោយផ្អែកលើតារាង Checklist (ឧបសម្ព័ន្ធទី២) មន្ត្រីអធិការកិច្ចត្រូវធ្វើការត្រួតពិនិត្យប្រព័ន្ធប្រព្រឹត្តកម្មសម្អាតទឹក ចាប់ពីប្រភពទឹករហូតដល់អាងប្រព្រឹត្តកម្ម អាងស្តុកទឹកស្អាត និងស្ថានីយបូមចែកចាយ។ ការត្រួតពិនិត្យ គឺត្រូវបញ្ជាក់អំពីគុណភាព និងនិរន្តរភាពនៃប្រភពទឹក, ការដំឡើងឧបករណ៍ បរិក្ខា សមស្របដែរឬទេ, ដំណើរការប្រព្រឹត្តកម្មសម្អាតទឹកតាមដំណាក់

កាលនីមួយៗសមស្របឬទេ, ការថែទាំប្រព័ន្ធ និងការធ្វើអនាម័យសមស្របឬទេ, ការស្តុកសារធាតុគីមីត្រឹមត្រូវឬទេ ឬ បញ្ហាផ្សេងៗទៀត។

ករណីចាំបាច់ ត្រូវបំពេញ ឬ កែសម្រួលទិន្នន័យនៃឧបសម្ព័ន្ធទី២ ឡើងវិញក្រោយពីពិនិត្យមើលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរួច។

មន្ត្រីអធិការកិច្ចត្រូវត្រួតពិនិត្យគុណភាពទឹកស្អាតក្នុងប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត (អាងស្តុកទឹកស្អាត) ដើម្បីបញ្ជាក់ពីគុណភាពទឹកស្អាតថា អនុលោម ឬមិនអនុលោមតាមស្តង់ដារទឹកស្អាតថ្នាក់ជាតិ។ ករណីលទ្ធផលវិភាគលើប៉ារ៉ាម៉ែត្រណាមួយមានការសង្ស័យ ឬ មិនអនុលោមតាមស្តង់ដារ, ការពិនិត្យតាមដានត្រូវចាប់ផ្តើម ដើម្បីស្វែងរកបញ្ហា ឬ មូលហេតុឱ្យបានច្បាស់លាស់។ ឧ. ការពិនិត្យតាមដានគុណភាពតាមផ្នែកនីមួយៗនៃប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត និងឬឧបសម្ព័ន្ធទី២ ប្រភពទឹកជាដើម។

- *កំណត់ត្រាអធិការកិច្ច (ឧបសម្ព័ន្ធទី១)*

ក្រោយពេលបញ្ចប់ការធ្វើអធិការកិច្ច ចាំបាច់ត្រូវរៀបចំកំណត់ត្រាអធិការកិច្ច ដោយក្នុងនោះត្រូវបង្ហាញពីសមាសភាពនៃក្រុមមន្ត្រីអធិការកិច្ច ពេលវេលាអធិការកិច្ច ស្ថានភាពជាក់ស្តែងនៃដំណើរការរបស់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (ចាប់ពីប្រភពទឹករហូតដល់ប្រព័ន្ធចែកចាយ រួមទាំងលទ្ធផលវិភាគគុណភាពទឹកនៅចុងបណ្តាញផងដែរ) ចំណុចខ្វះខាត បញ្ហាប្រឈម និងអនុសាសន៍សម្រាប់ធ្វើការកែតម្រូវ ព្រមទាំងការប្តេជ្ញាចិត្តរបស់ប្រតិបត្តិករក្នុងការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ទឹកស្អាតជូនអតិថិជន។ល។

## ២.៥. ការធ្វើរបាយការណ៍ស្នើសុំចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត

### *២.៥.១. របាយការណ៍ស្នើសុំចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត*

ករណីលទ្ធផលចុះអធិការកិច្ច ឃើញថា ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករអនុលោមតាមបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិដែលកំណត់ដោយក្រសួង, អគ្គនាយកដ្ឋានទឹកស្អាតត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ដើម្បីគោរពស្នើសុំចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតជូនប្រតិបត្តិករ។

ករណីលទ្ធផលចុះអធិការកិច្ច ឃើញថា ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករមានចំណុចមួយចំនួនមិនទាន់អនុលោមតាមបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិដែលកំណត់ដោយក្រសួង, អគ្គនាយកដ្ឋានទឹកស្អាតត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ដើម្បីគោរពស្នើសុំយោបល់បន្ថែមលើចំណុចដែលតម្រូវឱ្យប្រតិបត្តិករធ្វើការកែតម្រូវ ហើយក្រសួងត្រូវជូនដំណឹងប្រតិបត្តិករនូវចំណុចទាំងនោះ ដើម្បីធ្វើការកែតម្រូវ។ ចំពោះករណីនេះ មន្ទីររាជធានី-ខេត្តមាន

ភារកិច្ចតាមដានវឌ្ឍនភាពនៃការកែតម្រូវ និងរាយការណ៍ជូនក្រសួង (អគ្គនាយកដ្ឋានទឹកស្អាត) ជាប្រចាំ។ ក្រោយពីបានពិនិត្យឃើញថា ចំណុចទាំងអស់ដែលតម្រូវឱ្យធ្វើការកែតម្រូវ បានអនុវត្តរួចរាល់ហើយ អគ្គនាយកដ្ឋានទឹកស្អាតត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីគោរពស្នើសុំអនុវត្តនីតិវិធីបន្ត។

ករណី ការធ្វើអធិការកិច្ចអនុវត្តដោយមន្ទីររាជធានី-ខេត្ត, មន្ទីរត្រូវធ្វើរបាយការណ៍មកក្រសួងស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករ ដោយភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធទី១ ទី២ ទី៣ និងឧបសម្ព័ន្ធទី៤។

*២.៥.២. ការប្រជុំត្រួតពិនិត្យ និងវាយតម្លៃ (របាយការណ៍របស់មន្ទីររាជធានី-ខេត្ត)*

ក្រោយពេលដែលក្រសួង (អគ្គនាយកដ្ឋានទឹកស្អាត) ទទួលបានរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ចប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករ ដោយភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធទី១ ទី២ ទី៣ និងឧបសម្ព័ន្ធទី៤ ពីមន្ទីររាជធានី-ខេត្ត, អគ្គនាយកដ្ឋានទឹកស្អាតត្រូវពិនិត្យ ហើយសម្រេចចិត្តថា ចាំបាច់ត្រូវរៀបចំកិច្ចប្រជុំបន្ថែមជាមួយមន្ទីររាជធានី-ខេត្តឬទេ ឬក៏អាចរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីគោរពស្នើសុំអនុវត្តនីតិវិធីបន្ត (ចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាតជូនប្រតិបត្តិករ ឬ ជូនដំណឹងប្រតិបត្តិករពីចំណុចដែលត្រូវធ្វើការកែតម្រូវ)។

ករណីត្រូវរៀបចំកិច្ចប្រជុំជាមួយមន្ទីរ គឺអាចរៀបចំដោយផ្ទាល់ ឬ តាមអនឡាញ (online meeting) ដោយត្រូវរៀបចំកំណត់ហេតុប្រជុំឱ្យបានច្បាស់លាស់សម្រាប់ធ្វើជាមូលដ្ឋានក្នុងការធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីគោរពស្នើសុំអនុវត្តនីតិវិធីបន្ត។

*២.៥.៣. ការចេញ-ទទួលបានវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត*

ករណីក្រសួងពិនិត្យឃើញថា ដំណើរការផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករត្រឹមត្រូវស្របតាមបទដ្ឋានគតិយុត្តិ និងលក្ខណៈបច្ចេកទេសដែលកំណត់ដោយក្រសួង នោះក្រសួងត្រូវចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការផ្គត់ផ្គង់ទឹកស្អាត ជូនអ្នកកាន់ប្រកាសអនុញ្ញាតក្នុងកំឡុងពេលជាក់លាក់មួយដែលកំណត់ដោយក្រសួង ដោយគិតចាប់ពីថ្ងៃនៃការចុះអធិការកិច្ច។

## ៣. ការសិក្សាលើលក្ខណៈបច្ចេកទេស

### ៣.១. ការគណនាតម្រូវការទឹក

ការប៉ាន់ស្មានពីតម្រូវការទឹកសរុបដោយផ្អែកលើចំនួនប្រជាជនសរុបនៅក្នុងតំបន់សេវាកម្ម វាអាចបញ្ជាក់ឱ្យឃើញថាសមត្ថភាពប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតរបស់ប្រតិបត្តិករសមស្របទៅជាមួយនឹងតម្រូវការទឹកនាពេលបច្ចុប្បន្ន និងអនាគតដែរឬទេ។

- តម្រូវការទឹកបច្ចុប្បន្ន ( ១០ ) × ៤,៣ [នាក់] × ៦០ [លីត្រ/ថ្ងៃ] < ( ៤ )
- តម្រូវការទឹកពេលអនាគត ( ៣ ) × ៦០ [លីត្រ/ថ្ងៃ] < ( ៤ )

*សម្គាល់៖ (x): ជាលេខរៀងរបស់សូចនាករក្នុងឧបសម្ព័ន្ធទី២*

*( ៦០លីត្រ/នាក់/ថ្ងៃ ): ការគណនាក្នុងការសិក្សាសមិទ្ធិលទ្ធភាព (FS) ដោយក្រសួង*

*( ៥០-១០០លីត្រ/នាក់/ថ្ងៃ ): គោលការណ៍ណែនាំស្តីពីទឹកផឹកដោយអង្គការសុខភាពពិភពលោក ២០២២*

*៤.៣ នាក់/គ្រួសារជាមធ្យមៈ ជំរឿនចំនួនប្រជាជនឆ្នាំ២០១៩ របស់ក្រសួងផែនការ*

**** សមត្ថភាពនាពេលអនាគត មានន័យថាបរិមាណទឹកត្រូវការនៅពេលដែលប្រជាជនទាំងអស់នៅក្នុងតំបន់សេវាកម្មអាចប្រើប្រាស់បានគ្រប់គ្រាន់។ វាគឺជាសូចនាករសម្រាប់ផែនការពង្រីកនាពេលអនាគតដោយមិនតម្រូវឱ្យធ្វើការពង្រីកភ្លាមៗនោះទេ។*

**** រូបមន្តសន្មត់ទឹកប្រើប្រាស់នៅក្នុងផ្ទះ ដូច្នេះបើសិនមានរោងចក្រ ក្រុមហ៊ុន និងសណ្ឋាគារនៅក្នុងតំបន់សេវាកម្ម រូបមន្តខាងលើមិនអាចអនុវត្តបានទេព្រោះចំនួនប្រជាជនក្នុងមួយតំណគឺខ្ពស់។*

## ៣.២. ការគណនាទឹកបាត់បង់

ប្រព័ន្ធប្រព្រឹត្តកម្មដែលមិនបានតំឡើងកុងទ័រមេសម្រាប់ទឹកឆៅ បំពង់នាំទឹក និង បំពង់ចែកចាយទឹក គួរតែតំឡើងវាដើម្បីកំណត់នូវបរិមាណទឹក។ ទឹកបាត់បង់ (NRW) គឺជាភាពខុសគ្នារវាងបរិមាណទឹកចែកចាយនិងបរិមាណទឹកលក់ទៅកាន់អ្នកប្រើប្រាស់។

NRW [%]: ( ៩ ) = {១ - ( ៧ ) / ( ៦ )} × ១០០

*សម្គាល់៖ ទឹកបាត់បង់នៅប្រទេសអភិវឌ្ឍន៍៖ ប្រហែល ១០% ( ៥-២០% )*

*ទឹកបាត់បង់នៅប្រទេសកំពុងអភិវឌ្ឍន៍៖ ប្រហែល ៣០% ( ១៥-៦០% )*

## ៣.៣. ការគណនាការប្រើប្រាស់ថាមពលអគ្គិសនី

ការប្រើប្រាស់ថាមពលអគ្គិសនីសម្រាប់ទឹកចែកចាយ ១ ម៣ នៅប្រព័ន្ធប្រព្រឹត្តកម្មទឹកខ្នាតតូចនៅប្រទេសជប៉ុន គឺជាទូទៅ ៤០០-៦០០ (វ៉ាត់ម៉ោង/ម៣)។

*ការប៉ាន់ស្មានថាមពលពីការប្រើប្រាស់ប្រេង៖*

$Q_h$ = b × E / w ( លីត្រ/ម៉ោង )

$E_{amount}$ = E × $Q_t$ / $Q_h$

= w / b × $Q_t$ ( គីឡូវ៉ាត់ )

$Q_h$: ការប្រើប្រាស់ប្រេងក្នុងមួយម៉ោង ( លីត្រ/ម៉ោង )

$Q_t$: ( ១៣ ) ការប្រើប្រាស់ប្រេងសរុប ( ម៉ាស៊ីនភ្លើង ) ( លីត្រ/ឆ្នាំ )

b: ការប្រើប្រាស់ប្រេងដាក់លាក់ (ក្រាម/គីឡូវ៉ាត់ម៉ោង)

ករណី៖ (១៤) ≤ ២២ (គីឡូវ៉ាត់) , b = ៣១០ (ក្រាម/គីឡូវ៉ាត់ម៉ោង)

ករណី៖ ២២ គីឡូវ៉ាត់ < (១៤) ≤ ១៨៤ គីឡូវ៉ាត់, b = ៣០០ (ក្រាម/គីឡូវ៉ាត់ម៉ោង)

ករណី៖ ១៨៤ (គីឡូវ៉ាត់) < (១៤) , b = ២៧០ (ក្រាម/គីឡូវ៉ាត់ម៉ោង)

w: ទំនាញដី (លីត្រ/ម៉ោង) (ម៉ាស៊ូត: w = ៨៣០)

E: (១៤) សមត្ថភាពម៉ាស៊ីនភ្លើង (គីឡូវ៉ាត់)

$E_{amount}$: បរិមាណថាមពល (គីឡូវ៉ាត់)

គណនាការប្រើប្រាស់ថាមពលអគ្គិសនីក្នុង ១ (ម៉ែត្រគូប) ទឹកចែកចាយ។

{(១២) + $E_{amount}$} / (៦) × ១,០០០ (វ៉ាត់ម៉ោង / ម៉ែត្រគូប)

*** *បើសិនមានលំនៅដ្ឋាននៅក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបញ្ជាក់ថាបរិមាណអគ្គិសនីប្រើប្រាស់មិនរួមបញ្ចូលបរិមាណអគ្គិសនីប្រើប្រាស់នៅក្នុងផ្ទះនោះទេ។*

## ៣.៤. ការដាក់បញ្ចូលសារធាតុផ្តុំកករ និងសារធាតុសម្លាប់មេរោគ

បរិមាណនៃការដាក់បញ្ចូលសារធាតុផ្តុំកករដែលសមស្រប គឺអាស្រ័យទៅលើគុណភាពទឹកឆៅ។ បរិមាណនៃការដាក់បញ្ចូលសារធាតុផ្តុំកករ គឺប្រហាក់ប្រហែល ៤០ (មីលីក្រាម/លីត្រ)។ បើសិនជាដាក់លើស ៤០ (មីលីក្រាម/លីត្រ) ចាំបាច់ត្រូវពិនិត្យមើលពីការកកើតនៃកករនិងស្ថានភាពនៃការរងកករ។

បើសិន pH របស់ទឹកស្អាតទាប វាអាចមកពីការដាក់សារធាតុផ្តុំកករច្រើនពេក ឬ ការដាក់កំបោរមិនបានគ្រប់គ្រាន់។

ក្លរ ត្រូវបានដាក់ដើម្បីធានាថាមានក្លរសំណល់នៅចុងបណ្តាញក្នុងកម្រិត ០.១-១ (មីលីក្រាម/លីត្រ)។ បើសិនជាមិនមានការដាក់ក្លរនៅមុនអាងច្រោះទេ គួរបង្កើនការដាក់ក្លរដំបូងដើម្បីជំនួយដល់ការដកអាម៉ូញ៉ាក់ ម៉ង់កាណែស ដែក និង ស្ពែ។

## ៣.៥. ការសិក្សាលក្ខណៈប្រភពទឹក

ប្រភពទឹកនីមួយៗត្រូវបានកំណត់ដូចខាងក្រោម៖

ទន្លេ៖ ទឹកហូរតាមធម្មជាតិ និងបន្តជាខ្សែវែងឆ្លងកាត់ប្រទេសចូលទៅក្នុងសមុទ្រ

ស្ទឹង៖ ទឹកហូរតាមធម្មជាតិដែលហូរចូលទៅក្នុងទន្លេឬបឹង

ប្រឡាយ៖ ជាផ្លូវទឹកសិប្បនិម្មិតដែលជីកទៅក្នុងដីនិងបំពេញដោយទឹក សម្រាប់ទូកធ្វើដំណើរ ឬការប្រើប្រាស់នានា

បឹង៖ ផ្ទៃទឹកធំដែលព័ទ្ធជុំវិញដោយដី

ស្រះ៖ ផ្ទៃទឹកតូចដែលត្រូវបានបង្កើតឡើង

អណ្តូង៖ ទឹកក្រោមដីដែលទទួលបានពីការជីកទៅក្នុងដី

▪ បរិស្ថានជុំវិញប្រភពទឹកគឺស្អាត

ពិនិត្យថាមិនមានសម្រាមនៅជុំវិញប្រភពទឹក។ ហានិភ័យនៃការស្ទះបំពង់ដោយសារសម្រាម ។ត្រូវសម្អាតវា ព្រោះវាអាចនឹងធ្វើឱ្យម៉ាស៊ីនបូមខូច។ ត្រូវពិនិត្យថាមិនមានការកកើតនៃស្លែ និង មិនមានការហូរចូលនៃទឹកកខ្វក់ពីលំនៅដ្ឋាន ឬ រោងចក្រដែលនៅជុំវិញ។ វាអាចបង្កឱ្យមានការ បំពុលទឹកដូចជាតម្លៃ pH និងការកើនឡើងនូវភាពល្អក់។

▪ លក្ខណៈប្រភពទឹក

*ទន្លេ និង ស្ទឹង និង ប្រឡាយ*

ដោយសារភាពល្អក់នៃទឹកទន្លេ ប្រែប្រួលទៅតាមបរិមាណទឹកភ្លៀង ប្រព័ន្ធត្រូវបានដំណើរ ការដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃគុណភាពទឹកឆៅ។ បញ្ហាមួយទៀតគឺផលប៉ះពាល់លើ គុណភាពទឹកដែលបង្កដោយការបំពុលពីទឹកកខ្វក់លំនៅដ្ឋាននិងរោងចក្រ។

*បឹង និង ស្រះ*

គុណភាពទឹកបឹង គឺប្រហាក់ប្រហែលទៅនឹងទឹកទន្លេ ប៉ុន្តែទឹកបឹងមានភាពល្អក់ទាបជាង ទឹកទន្លេដោយសារតែរយៈពេលនៃការហូរគឺវែង។ ដោយឡែក សារធាតុចិញ្ចឹមដែលកើតឡើង ដោយសរីរាង្គនិងដីខូច អាចបង្កឱ្យគុណភាពទឹកធ្លាក់ចុះនិងមានស្លែ។

*ទឹកអណ្តូង*

ជាទូទៅ ទឹកក្រោមដី គឺជាប្រភពទឹកដែលមានគុណភាពល្អនិងមានបរិមាណ គុណភាព សីតុណ្ហភាពថេរជាងទឹកទន្លេ។ ម៉្យាងវិញទៀត ដោយអាស្រ័យទៅលើស្ថានភាពភូមិសាស្ត្រ សារ ធាតុអសរីរាង្គដូចជាកាល់ស្យូម ម៉ាញ៉េស្យូម ដែក និងម៉ង់កាណែស គឺរលាយទៅក្នុងទឹកក្រោមដី។

## ៣.៦. ការសិក្សាអំពីស្ថានភាពស្ថានីយបូមទឹកឆៅ

▪ ស្ថានីយបូមទឹកឆៅ

ប្រភេទស្ថានីយបូមទឹកឆៅចំបងនៅកម្ពុជា មានស្ថានីយនឹងថ្កល់និងស្ថានីយបណ្តែត។ ប្រភេទស្ថានីយនឹងថ្កល់ គឺមានភាពងាយស្រួលក្នុងការថែទាំ ព្រោះម៉ាស៊ីនបូមទឹកអាចត្រូវបាន តំឡើងនៅទីតាំងមួយងាយស្រួលនៅលើដី ប៉ុន្តែកំពស់បឺតអាចមានការប្រែប្រួលទៅតាមការឡើង ចុះនៃកំពស់ទឹកប្រភព។ ប្រភេទស្ថានីយបណ្តែត មានភាពពិបាកក្នុងការប្រើប្រាស់ព្រោះម៉ាស៊ីន បូមទឹក ត្រូវបានតំឡើងនៅក្នុងរោងបណ្តែតលើទឹក ប៉ុន្តែកំពស់បឺតគឺមានស្ថេរភាព។




រូបភាពទី២៖ ប្រភេទស្ថានីយបូមទឹកផៅ

▪ កំពស់តម្រូវ

តម្លៃនេះមានសារៈសំខាន់ ក្នុងការកំណត់ថាតើការជ្រើសរើសម៉ាស៊ីនបូមត្រឹមត្រូវឬអត់។ ក្នុងករណីស្ថានីយនឹងថ្កល់ កំពស់បឺតពិតប្រាកដ ($h_{as}$)នៅរដូវក្តៅ គួរតែត្រូវបានយកមកពិចារណាក្នុងជ្រើសរើសម៉ាស៊ីនបូម។




រូបភាពទី៣៖ កំពស់តម្រូវ

▪ ម៉ាស៊ីនបូមទឹកផៅ

ចំពោះប្រភេទនៃម៉ាស៊ីនបូមទឹកផៅ មានដូចជាប្រភេទរង្វិលចាកផ្ចិត និងជ្រមុជក្នុងទឹក។ ត្រូវត្រៀមម៉ាស៊ីនបូមទឹកបម្រុងក្នុងករណីខូច។




រូបភាទី៤៖ ប្រភេទម៉ាស៊ីនបូមទឹកផៅ

*ចំណុចត្រូវពិនិត្យ*

១) ការតំឡើងត្រឹមត្រូវ

ម៉ាស៊ីនបូមទឹកផៅ ត្រូវបានចាប់ជាមួយនឹងប៊ូឡុងឬទេ។ ការមិនចាប់ឱ្យជាប់ នឹងបង្កឱ្យមានការញ័រ។ បើសិនម៉ូទ័រ ត្រូវបានប្រើប្រាស់នៅខាងក្រៅ សមត្ថភាពក្នុងការការពារពីការជ្រាបទឹកត្រូវតែតម្រូវ។ (IP៥៤ ឬខ្ពស់ជាងនេះ)

២) ផ្នែកបង្វិលនិងតំណភ្ជាប់ថាមពល ត្រូវបានការពារ

ពិនិត្យថាផ្នែកបង្វិលត្រូវបានការពារដោយគម្រប ហើយតំណភ្ជាប់ថាមពល ត្រូវបានការពារ។ ការបើកចំហរផ្នែកបង្វិល អាចមានហានិភ័យនៃការធ្លាក់កំទេចកំទីចូលទៅក្នុងម៉ាស៊ីន។ ហើយអាចមានហានិភ័យនៃការឆក់ចរន្តអគ្គិសនីបើសិនតំណភ្ជាប់ថាមពល ត្រូវបានដាក់ចំហរ។

៣) ភាពញ័ររបស់ម៉ាស៊ីនបូម និងសំលេងដំណើរការល្អ

ភាពញ័រនិងសំលេងខុសពីធម្មតា កើតមានឡើងដោយសារការដំណើរការមិនប្រក្រតីនៃឧបករណ៍ដែលអាចធ្វើឱ្យខូច។ វាជាការល្អក្នុងការប្រើឧបករណ៍ស្តាប់សំលេងពិសេសត្រង់ចំណុចប៉ាដាង។

៤) សីតុណ្ហភាពម៉ាស៊ីនបូម គឺសមស្រប

ប៉ះប៉ាដាងនិងម៉ូទ័រដើម្បីប្រាកដថាវាមិនក្តៅពេក។ បើសិនជាមានទែម៉ូម៉ែត្រ ត្រូវប្រើវា។ ការកើនឡើងកំដៅនៃម៉ូទ័រនិងប៉ាដាងខុសធម្មតាអាចធ្វើឱ្យឧបករណ៍ខូច។ ទោះបីវាអាចមានការប្រែប្រួលអាស្រ័យលើឧបករណ៍ សីតុណ្ហភាពសមស្របសម្រាប់ម៉ូទ័រនិងប៉ាដាងជាទូទៅ +៤០°C សីតុណ្ហភាពក្នុងបន្ទប់។

▪ ទូរបញ្ជាម៉ាស៊ីនបូមទឹកឆៅ

ប្រភេទនៃទូបញ្ជា បង្ហាញថាតើវាជាប្រភេទ Direct-Online, Star Delta, ឬ Inverter។

Direct Online: *វិធីសាស្ត្រដែលតង់ស្យុងផ្គត់ផ្គង់ជាមពល ត្រូវបានអនុវត្តដោយផ្ទាល់ចំពោះម៉ូទ័រ ដើម្បីចាប់ផ្តើមវា។ ចរន្តនៅពេលចាប់ផ្តើម គឺខ្ពស់ជាងចរន្តដែលបានកំរិត ៦ ទៅ ១០ដង។*

Star-Delta: *វិធីសាស្ត្រនេះកាត់បន្ថយចរន្តនៅពេលចាប់ផ្តើម ដោយចាប់ផ្តើមជាមួយstar connectionនៅអំឡុងពេលចាប់ផ្តើមហើយប្តូរទៅdelta connectionនៅអំឡុងពេលប្រតិបត្តិការ។ ចរន្តនៅពេលចាប់ផ្តើម គឺ១/៣ ហើយកំលាំងបង្វិលជុំនៅពេលចាប់ផ្តើមត្រូវបានកាត់បន្ថយ១/៣នៃការចាប់ផ្តើមដោយDirect Online។*

Inverter: *តង់ស្យុងនិងហ្វ្រេកង់ អាចត្រូវបានសម្រួលដើម្បីចាប់ផ្តើមម៉ូទ័រនៅកម្រិតតង់ស្យុងនិងហ្វ្រេកង់ទាបជាងការផ្គត់ផ្គង់ជាមពលដែលមានលក្ខណៈអាជីវកម្ម ជាលទ្ធផលកាត់បន្ថយចរន្តនៅពេលចាប់ផ្តើម។*

*ចំណុចត្រូវពិនិត្យ*

១) ការតំឡើងត្រឹមត្រូវ

មិនត្រូវតំឡើងនៅទីតាំងដែលមានទឹក ដើម្បីការពារការលេចចរន្តអគ្គិសនី ឬគ្រោះថ្នាក់ដោយសារឆ្លងចរន្តអគ្គិសនី។ ចំបាច់ត្រូវចាប់ជាមួយប៊ូឡុងដើម្បីការពារធ្លាក់។

២) ភាពស្អាតនៅក្នុងទូបញ្ជា

ពិនិត្យមើលថាមិនមានធូលី សត្វល្អិត សម្រាមនៅទូបញ្ជា។ ចាំបាច់ត្រូវរក្សាភាពស្អាតចំពោះផ្នែកខាងក្នុងនៃទូបញ្ជា ដើម្បីការពារគ្រោះថ្នាក់អគ្គិសនីដូចជាការលេចធ្លាយចរន្តអគ្គិសនី និងការឆ្លងអគ្គិសនី។

៣) គ្រឿងបង្គុំដែលសត្វល្អិតឬសត្វពាហនៈមិនចូលបាន

មិនមានចន្លោះប្រហោងនៅក្នុងទូបញ្ជា លើកលែងសម្រាប់ខ្យល់ចេញចូល ដើម្បីការពារគ្រោះថ្នាក់អគ្គិសនីដូចជាការលេចធ្លាយចរន្តអគ្គិសនី និងការឆ្លងចរន្តអគ្គិសនី។

៤) ខ្សែភ្លើងសមស្រប

ពិនិត្យមើលថាមិនមានការខូចឬស្នាមប្រេះសំបកខ្សែភ្លើង។ ដើម្បីការពារធ្លុះឬរហែកសំបកខ្សែភ្លើង ត្រូវការពារនិងដាក់ទម្រខ្សែភ្លើង ដូច្នេះមិនមានបន្ទុកទាញ។

▪ បណ្តាញនាំទឹកឆៅ

*ចំណុចត្រូវពិនិត្យ*

១) ស្ថានភាពបំពង់និងវ៉ានគឺល្អ

ពិនិត្យមើលភាពលេចធ្លាយដោយសារការធ្វើឱ្យខូច ឬ ភាពចាស់នៃបំពង់ឬវ៉ាន ឬតំណភ្ជាប់មិនបានល្អ

២) ទម្របំពង់

បើសិនមិនមានទម្របំពង់ ការរំញ័រនិងកត្តាផ្សេងៗអាចធ្វើឱ្យខូចបំពង់និងគ្រឿងបង្គុំផ្សេងៗ

៣) វ៉ានបញ្ចេញទឹកនៅលើបំពង់បញ្ជូនទឹក

ត្រូវតំឡើងវ៉ានបញ្ចេញទឹកដើម្បីបញ្ឈប់ទឹកនិងរៀបចំសម្រាប់ការសម្រួលលំហូរទឹកនៅពេលថែទាំជួសជុលម៉ាស៊ីនបូមទឹក

## ៣.៧. ការសិក្សាអំពីដំណើរការប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត (Conventional)

▪ បរិក្ខារបញ្ចូលសារធាតុគីមី

១) ធុងបន្តក់

ធុងបន្តក់ឬម៉ូទ័របន្តក់ត្រូវបានតំឡើងដើម្បីរក្សានូវស្ថេរភាពនៃកម្រិតនៃការបន្តក់សារធាតុគីមី។ ធុងបន្តក់ ត្រូវបំពាក់មកជាមួយនូវវ៉ានបណ្តែតដើម្បីធានាថាកំពស់សូលុយស្យុងថេរ។




រូបភាពទី៥៖ ធុងបន្តក់

២) កម្រិតលាយ

ពិនិត្យមើលថាប្រតិបត្តិករបានប្រើជញ្ជីងដើម្បីឱ្យកម្រិតលាយមានស្ថេរភាព។ បើសិនមានការលំបាកក្នុងការសម្រួលអត្រាបញ្ចូលសារធាតុគីមី វាអាចមានប្រសិទ្ធភាពចំពោះការសម្រួលកំហាប់សារធាតុគីមីដែលត្រូវបានប្រើប្រាស់។

៣) ការស្តុក

ក្នុងករណីមានការយឺតយ៉ាវឬរាំងស្ទះដល់ការផ្គត់ផ្គង់សារធាតុគីមីដោយសារគ្រោះមហន្តរាយ វាមានភាពចាំបាច់ក្នុងការស្តុកសារធាតុគីមី ដូច្នេះប្រព័ន្ធប្រព្រឹត្តកម្មមិនមានការរាំងស្ទះ។ ខាងក្រោមនេះ គឺជាសេចក្តីណែនាំអំពីការស្តុកៈ

តារាងទី២ៈ សេចក្តីណែនាំអំពីការស្តុក

| សារធាតុគីមី | ការស្តុក |
| --- | --- |
| ក្លរ | ១០ថ្ងៃ |
| សារធាតុគ្រប់គ្រងpH | ៣០ថ្ងៃ ឬ ១០ថ្ងៃ<br>* បើសិនវាមិនបន្តក់ជាប់រហូត ១០ ថ្ងៃគឺគ្រប់គ្រាន់ |
| សារធាតុចាប់កករ | ៣០ ថ្ងៃ |

<ប្រភពៈ លក្ខណៈវិនិច្ឆ័យសម្រាប់រចនាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត/សមាគមទឹកស្អាតប្រទេសជប៉ុន>

- អាងទទួលទឹក

អាងទទួលទឹក គួរមានផ្ទៃមុខកាត់និងរយៈពេលហូរឆ្លងកាត់សមស្របដើម្បីរក្សាស្ថេរភាពនៃកំពស់ទឹក។ សម្រាប់ទស្សនៈនៃភាពប្រែប្រួលកំពស់ទឹកនិងការគ្រប់គ្រងថែទាំ ជម្រៅអាងត្រូវបានពិចារណាក្នុងកម្រិត ៣–៥ ម៉ែត្រ។ ក្នុងករណីប្រព័ន្ធប្រព្រឹត្តកម្មខ្នាតតូច ត្រូវយកចិត្តទុកដាក់ចំណុចនេះ ពីព្រោះជម្រៅកាន់តែជ្រៅនឹងធ្វើឱ្យផ្ទៃមុខកាត់កាន់តែតូច ហើយការគ្រប់គ្រងថែទាំក៏កាន់តែលំបាក។

*រយៈពេលហូរឆ្លងកាត់*

រយៈពេលហូរឆ្លងកាត់ គឺជារយៈពេលដែលទឹកត្រូវបានរក្សាទុកនៅក្នុងអាង ឬរយៈពេលចាប់ពីពេលដែលទឹកហូរចូលក្នុងអាងរហូតដល់វាហូរចេញពីអាង។ វាអាចត្រូវបានគិតថាជារយៈពេលដែលទឹកហូរបំពេញអាង។ សម្រាប់គ្រឿងបង្គុំ ដូចជាធុងឬអាង សមត្ថភាពគឺមានសារៈសំខាន់ក្នុងការធ្វើផែនការ ហើយរយៈពេលហូរឆ្លងកាត់ ដែលត្រូវបានគណនាដោយយកមាឌចែកនឹងលំហូរ ត្រូវបានប្រើប្រាស់ជាសូចនាករសម្រាប់គណនាសមត្ថភាពរបស់អាងនីមួយៗ។

តារាងទី៣ៈ រយៈពេលហូរឆ្លងកាត់ដែលសមស្រប

| | រយៈពេលហូរឆ្លងកាត់ |
| --- | --- |
| អាងទទួលទឹក | ១,៥នាទី ឬ លើសពីនេះ |
| អាងលាយសារធាតុគីមី | ១-៥ នាទី |
| អាងចាប់កករ | ២០-៤០ នាទី |
| អាងស្តុកទឹកស្អាត | ១២ ម៉ោង ឬ លើសពីនេះ* |

**បើសិនអាងស្តុកទឹកស្អាត បម្រើការដូចអាងចែកចាយទឹកស្អាតផងដែរ។ បើសិនអាងចែកចាយទឹក ដាច់ដោយឡែកពីគ្នា រយៈពេលហូរឆ្លងកាត់នៃអាងស្តុកទឹកគឺ១ម៉ោង។*

<ប្រភព៖ លក្ខណៈវិនិច្ឆ័យសម្រាប់រចនាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត/សមាគមទឹកស្អាតប្រទេសជប៉ុន>

▪ អាងលាយសារធាតុគីមី

ពេលវេលាប្រតិកម្មរវាងសារធាតុចាប់កករនិងទឹកឆៅ គឺតិចជាង១នាទី ហេតុដូច្នេះការលាយគ្នាដោយរហ័សនិងភ្លាមៗបន្ទាប់ពីចាក់បញ្ចូលគឺមានភាពចាំបាច់ដើម្បីបន្សាចសារធាតុចាប់កករឱ្យបានគ្រប់សព្វ។

*ចំណុចត្រូវពិនិត្យ*

១) សារធាតុគីមីត្រូវបានចាក់បញ្ចូលនៅទីកន្លែងសមស្រប

ពិនិត្យថាសារធាតុគីមីនីមួយៗត្រូវបានចាក់នៅទីតាំងសមស្រប។ ទីតាំងត្រូវមានល្បឿនលំហូរទឹកគ្រប់គ្រាន់និងការលាយគ្រប់គ្រាន់នៃសារធាតុគីមី។ សារធាតុចាប់កករ គួរត្រូវបានចាក់បញ្ចូលទៅក្នុងទឹកដែលបានមានpHសមស្របសម្រាប់ការចាប់កករ។

២) ការលាយចូលគ្នាដោយរហ័សនិងភ្លាមៗបន្ទាប់ពីការចាក់បញ្ចូលសារធាតុចាប់កករ

ពិនិត្យថាការលាយគ្នាគឺរហ័សក្រោយពីការចាក់បញ្ចូលនៃសារធាតុចាប់កករ។

▪ អាងផ្តុំកករ

កករតូចៗ កើតមានឡើងនៅក្នុងអាងលាយ និងបន្តក្លាយទៅជាកករធំៗ។ ជាមួយនិងកម្លាំងលាយសមស្រប កករនឹងរីកធំទៅៗ ប៉ុន្តែបើកម្លាំងខ្លាំងពេក នឹងធ្វើឱ្យកករបែកវិញ។

*ចំណុចត្រូវពិនិត្យ*

១) បញ្ជាក់ថាកកររីកធំឡើងតាមរយៈការកូរ

កករអាចនឹងត្រូវបានកំទេចបើសិនលំហូរទឹកលឿន។

២) លំហូរទឹកគឺស្មើៗគ្នា

ពិនិត្យពីការជាប់គាំង ឬការរំខានផ្សេងៗដល់លំហូរទឹក ដូចជាការហូរចូលនៃទឹកភ្លៀង ឬការខូចខាតនៃគ្រឿងបង្គុំអាងជាដើម។

៣) កករត្រូវបានបង្កើតឡើងដោយល្អ

▪ អាងរងកករ

អាងរងកករ គឺជាដំណើរការដែលមានចេតនាបន្ថយល្បឿនលំហូរទឹកដើម្បីបែងចែករវាងភាពល្អក់និងសារធាតុផ្សេងទៀតដោយទំនាញដី។ ទោះបីជាវាត្រូវការទីតាំងធំព្រោះសមត្ថភាពប្រព័ន្ធប្រព្រឹត្តកម្មត្រូវបានកំណត់ដោយក្រឡាផ្ទៃ វាមានអត្ថប្រយោជន៍នៃការប្រើប្រាស់ថាមពល

ទាបសម្រាប់ការបំបែកអង្គធាតុរាវ-អង្គធាតុរឹងដ៏មានប្រសិទ្ធភាព និងមានសមត្ថភាពក្នុងការទប់ទល់នឹងការប្រែប្រួលនៃទឹកផៅ។




រូបភាពទី៦៖ វិធីសាស្ត្រនៃការរងកករ

*ចំណុចត្រូវពិនិត្យ*

១) លំហូរគឺថេរនៅក្នុងអាងនីមួយៗ

បរិមាណទឹកនៅក្នុងអាងនីមួយៗ គួរតែដូចគ្នាបើសិនជាមានអាងចាប់ពី ២ ឡើងទៅ។ ពិនិត្យថាមិនមានលំហូរទឹកមិនមានតុល្យភាពដោយសារមានការរាំងស្ទះនៅតាមជញ្ជាំងនិងបំពង់បង្ហូរទឹកចេញ។

២) ស្ថានភាពនៃទឹកហូរចេញគឺល្អ

ពិនិត្យថាមិនមានកករធំៗហូរចេញទៅអាងបន្ទាប់។ កករធំៗដែលហូរចេញពីអាង នឹងបង្កើនបន្ទុកដល់អាងច្រោះ។

៣) បរិមាណនៃភក់នៅបាតអាងគឺទាប

បើសិនជាមានភក់ច្រើននៅបាតអាង វានឹងផុលឡើងដោយសារការប្រែប្រួលនៃលំហូរទឹក ដូច្នេះភក់គួរត្រូវបានបង្ហូរចេញនិងសំអាតជារឿយៗ។

៤) វ៉ាននិងបំពង់បង្ហូរចេញ

ពិនិត្យថាមានបំពង់និងវ៉ានបង្ហូរភក់ ហើយពួកវាមានសមត្ថភាពក្នុងការបង្ហូរភក់ចេញដោយសារមានជម្រាលនៅបាតអាង។ល។

*បន្ទះពង្រង*

បន្ទះពង្រង គឺជាឧបករណ៍ដែលបង្កើនផ្ទៃរងនិងធ្វើឱ្យប្រសើរឡើងនៃសមត្ថភាពប្រព្រឹត្តកម្ម ដោយការតំឡើងនូវបន្ទះពង្រងទ្រេតជាច្រើនបន្ទះនៅក្នុងអាងរង។ ដូចបានបង្ហាញនៅក្នុងរូបភាព ៦-៧ នៅពេលបន្ទះពង្រងទ្រេតត្រូវបានតំឡើងនៅក្នុងអាងរងជាមួយនឹងកំពស់ H ល្បឿនរងនឹងបង្រួមមកត្រឹមh/Hដង។ នេះមានន័យថាផ្ទៃរងបានកើនឡើងH/h ដង។




រូបភាពទី៧៖ មុខងារនៃបន្ទះពង្រង

*Surface loading*

Surface loading គឺជាសូចនាករគ្រឹះនៅពេលពិចារណាអត្រានៃការដកចេញកករនៅក្នុងអាងរង។ ដូចបានបង្ហាញនៅក្នុងរូបភាព ៦-៨ Surface loading សំដៅដល់ល្បឿននៃការរង ដែលភាគល្អិតហូរចូលពីផ្នែកខាងលើនៃអាងរង រងចុះទៅដល់បាតអាងត្រឹមចុងនៃអាងរង។




រូបភាពទី៨៖ Surface Loading

មានវិធីសាស្ត្របីយ៉ាងសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការដកចេញកករ

១. បង្កើនទំហំការរ៉ែនៃអាងរង (បន្ទះពង្រង)

២. បង្កើនល្បឿនរងនៃកករ V

៣. បន្ថយបរិមាណហូរចូល

តារាងទី៤៖ surface loading និង ល្បឿនលំហូរដែលសមស្រប

| | Surface loading | ល្បឿនលំហូរ |
|---|---|---|
| អាងរង លំហូរផ្តេក | ១៥ ~ ៣០ មីលីម៉ែត្រ/នាទី | ០,៤ ម៉ែត្រ/នាទី ឬ តិចជាងនេះ |
| បន្ទះពង្រង (ផ្តេក) | ៤ ~ ៩ មីលីម៉ែត្រ/នាទី | ០,៦ ម៉ែត្រ/នាទី ឬ តិចជាងនេះ |
| បន្ទះពង្រង (ក្រោមឡើងលើ) | ៧ ~ ១៤ មីលីម៉ែត្រ/នាទី | ៨០ មីលីម៉ែត្រ/នាទី ឬ តិចជាងនេះ |

<ប្រភព៖ លក្ខណៈវិនិច្ឆ័យសម្រាប់រចនាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត/សមាគមទឹកស្អាតប្រទេសជប៉ុន>

ឧ. អាងរង លំហូរផ្ដេក




Q = ១៥០ (ម៉ែត្រគូប/ម៉ោង), L = ២០ (ម៉ែត្រ), W = ៥ (ម៉ែត្រ)

$V_0$ = Q / A

$V_0$ = ១៥០ / (២០ × ៥) (ម៉ែត្រ/ម៉ោង)

$V_0$ = ១,៥ ×១.០០០/៦០ = ២៥ (មីលីម៉ែត្រ/នាទី)

ឧ. បន្ទះពង្រឹង

Q = ៣០០ (ម៉ែត្រគូប/ម៉ោង), $L_t$ = ២០ (ម៉ែត្រ), $L_p$=១០, W = ៥ (ម៉ែត្រ)

$H_p$ = ៣ (ម៉ែត្រ), h = ០,៣ (ម៉ែត្រ)

$V_0$ = Q / A

$V_0$ = ៣០០ / {(២០ – ១០) × ៥ + ១០ × ៥ × (៣ / ០,៣)} (ម៉ែត្រ/ម៉ោង)

$V_0$ = ០,៥៥ ×១.០០០ / ៦០ = ៩,២ (មីលីម៉ែត្រ/នាទី)

▪ អាងច្រោះ

នៅក្នុងអាងច្រោះខ្សាច់លឿន ភាពល្អក់ក្នុងទឹកឆៅត្រូវបានផ្ដុំជាកករដោយសារជាតុគីមី និងច្រោះដោយស្រទាប់ខ្សាច់ក្រួសក្នុងកម្រិតល្បឿនសមស្រប។ អត្រាច្រោះជាទូទៅគឺ១២០-១៥០ ម៉ែត្រ/ថ្ងៃ។

១) កំពស់ខ្សាច់

ខ្សាច់ស៊ីលីការ គឺជាទូទៅត្រូវបានប្រើប្រាស់ជាខ្សាច់ច្រោះ។ វាទាមទារឱ្យមានភាពខុសគ្នាតិចតួចនៅក្នុងទំហំខ្សាច់និងភាគល្អិតផ្សេងទៀតតិចតួច។ កម្រាស់ស្រទាប់ខ្សាច់ស្ដង់ដារ គឺប្រហាក់ប្រហែល (ទំហំប្រសិទ្ធភាព) × ១,០០០ មីលីម៉ែត្រ។

២) វិធីសាស្ត្រលាងខ្សាច់

ការលាងសំអាតល្អឬមិនល្អ ជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការច្រោះ។ វាមានសារៈសំខាន់ថាស្រទាប់ច្រោះទាំងមូល ត្រូវបានលាងសំអាតយ៉ាងល្អ។ ការលាងសំអាតមិនគ្រប់គ្រាន់ អាចបណ្ដាលឱ្យមានបញ្ហានានាកើតឡើងដូចជាបន្ថយពេលវេលាច្រោះ ការធ្លាក់ចុះនៃបរិមាណទឹកច្រោះរួច និង ដុំភក់។




រូបភាពទី៩៖ វិធីសាស្ត្រលាងអាងច្រោះ

*ចំណុចត្រូវពិនិត្យ*

១) ស្ថានភាពនៃខ្សាច់ផ្ទៃខាងលើគឺល្អ

ពិនិត្យថាមិនមានស្លែកើតឡើង។ បើសិនជាមានស្លែកើតឡើងត្រូវបង្កើនបរិមាណក្លរដំបូង ព្រោះក្លរប្រសិទ្ធភាពមិនមានទៀតទេ។ ត្រូវពិនិត្យដុំកក់និងស្នាមប្រេះនៅលើផ្ទៃនៃស្រទាប់ច្រោះ។ ប្រសិនបើដុំកក់ត្រូវបានទុកចោលដោយមិនបានយកចិត្តទុកដាក់ សមត្ថភាពច្រោះនឹងត្រូវបានកាត់បន្ថយ ហើយពំនូកកក់នៃស្រទាប់ច្រោះនឹងកើតឡើង ដូច្នេះវិធីសាស្ត្រលាងសម្អាតចាំបាច់ត្រូវពិនិត្យឡើងវិញ។

▪ អាងស្តុកទឹកស្អាត

អាងស្តុកទឹកស្អាត គឺជាដំណាក់កាលចុងក្រោយនៃប្រព័ន្ធប្រព្រឹត្តកម្មទឹក ហើយត្រូវបានសាងសង់ដើម្បីធានាឱ្យបាននូវសុវត្ថិភាពទាំងអនាម័យនិងសំណង់ រឹងមាំគ្រប់គ្រាន់ និង មិនជ្រាបទឹក។

*ចំណុចត្រូវពិនិត្យ*

១) ស្ថានភាពគឺស្អាតនិងសុវត្ថិភាព

ពិនិត្យមើលថាសំណង់ត្រូវបានការពារពីទឹកភ្លៀង ធូលីនិងសត្វល្អិតហើយមិនត្រូវផ្ទាល់ពីពន្លឺព្រះអាទិត្យ។

២) ស្ថានភាពសំណង់គឺល្អ

ពិនិត្យមើលស្នាមប្រេះនៅលើសំណង់និងការលេចធ្លាយដោយសារការបាក់បែក ឬភាពចាស់នៃបំពង់ វ៉ាន ឬការតភ្ជាប់មិនល្អ។

៣) ទីតាំងនិងគ្រឿងបង្គុំនៃបំពង់គឺសមស្រប

ពិនិត្យគ្រឿងបង្គុំនៃអាងនិងទីតាំងនៃបំពង់ទឹកចូលនិងចេញដើម្បីធានាថាទឹកនៅក្នុងអាងមិននៅទ្រឹង។

### ៣.៨. ការសិក្សាលើប្រព័ន្ធចែកចាយទឹកស្អាត

▪ ម៉ាស៊ីនបូមចែកចាយ

១) ការតំឡើងត្រឹមត្រូវ

ម៉ាស៊ីនបូមចែកចាយ ត្រូវបានចាប់ជាមួយនឹងប៊ូឡុងឬទេ។ ការមិនចាប់ឱ្យជាប់ នឹងបង្កឱ្យមានការញ័រ។ បើសិនម៉ូទ័រ ត្រូវបានប្រើប្រាស់នៅខាងក្រៅ សមត្ថភាពក្នុងការការពារពីការជ្រាបទឹកត្រូវតែតម្រូវ។ (IP54 ឬខ្ពស់ជាងនេះ)

២) ផ្នែកបង្វិលនិងតំណភ្ជាប់ថាមពល ត្រូវបានការពារ

ពិនិត្យថាផ្នែកបង្វិលត្រូវបានការពារដោយគម្រប ហើយតំណភ្ជាប់ថាមពល ត្រូវបានការពារ។ ការបើកចំហរផ្នែកបង្វិល អាចមានហានិភ័យនៃការធ្លាក់កំទេចកំទីចូលទៅក្នុងម៉ាស៊ីន។ ហើយអាចមានហានិភ័យនៃការឆក់ចរន្តអគ្គិសនីបើសិនតំណភ្ជាប់ថាមពល ត្រូវបានដាក់ចំហរ។

៣) ភាពញ័ររបស់ម៉ាស៊ីនបូម និងសំលេងដំណើរការល្អ

ភាពញ័រនិងសំលេងខុសពីធម្មតា កើតមានឡើងដោយសារការដំណើរការមិនប្រក្រតីនៃឧបករណ៍ដែលអាចធ្វើឱ្យខូច។ វាជាការល្អក្នុងការប្រើឧបករណ៍ស្តាប់សំលេងពិសេសត្រង់ចំណុចប៉ាដាង។

៤) សីតុណ្ហភាពម៉ាស៊ីនបូម គឺសមស្រប

ប៉ះប៉ាដាងនិងម៉ូទ័រដើម្បីប្រាកដថាវាមិនក្តៅពេក។ បើសិនជាមានទែម៉ូម៉ែត្រ ត្រូវប្រើវា។ ការកើនឡើងកំដៅនៃម៉ូទ័រនិងប៉ាដាងខុសធម្មតាអាចធ្វើឱ្យឧបករណ៍ខូច។ ទោះបីវាអាចមានការប្រែប្រួលអាស្រ័យលើឧបករណ៍ សីតុណ្ហភាពសមស្របសម្រាប់ម៉ូទ័រនិងប៉ាដាងជាទូទៅ +៤០°C សីតុណ្ហភាពក្នុងបន្ទប់។

▪ ទូរបញ្ជាម៉ាស៊ីនបូមចែកចាយ

*ចំណុចត្រូវពិនិត្យ*

១) ការតំឡើងត្រឹមត្រូវ

មិនត្រូវតំឡើងនៅទីតាំងដែលមានទឹក ដើម្បីការពារការលេចចរន្តអគ្គិសនី ឬគ្រោះថ្នាក់ដោយសារសៀគ្វីឆ្លងភ្លើង។ ចំបាច់ត្រូវចាប់ជាមួយប៊ូឡុងដើម្បីការពារធ្លាក់។

២) ភាពស្អាតនៅក្នុងទូបញ្ជា

ពិនិត្យមើលថាមិនមានធូលី សត្វល្អិត សម្រាមនៅទូបញ្ជា។ ចាំបាច់ត្រូវរក្សាភាពស្អាតចំពោះផ្នែកខាងក្នុងនៃទូបញ្ជា ដើម្បីការពារគ្រោះថ្នាក់អគ្គិសនីដូចជាការលេចធ្លាយចរន្តអគ្គិសនី និងសៀគ្វីឆ្លងភ្លើង។

៣) គ្រឿងបង្គុំដែលសត្វល្អិតឬសត្វពាហនៈមិនចូលបាន

មិនមានចន្លោះប្រហោងនៅក្នុងទូបញ្ជា លើកលែងសម្រាប់ខ្យល់ចេញចូល ដើម្បីការពារគ្រោះថ្នាក់អគ្គិសនីដូចជាការលេចធ្លាយចរន្តអគ្គិសនី និងសៀគ្វីឆ្លងភ្លើង។

៤) ខ្សែភ្លើងសមស្រប

ពិនិត្យមើលថាមិនមានការខូចឬស្នាមប្រេះសំបកខ្សែភ្លើង។ ដើម្បីការពារឆ្កូតឬរហែកសំបកខ្សែភ្លើង ត្រូវការពារនិងដាក់ទម្រខ្សែភ្លើង ដូច្នេះមិនមានបន្ទុកទាញ។

- អាងអាកាស

*ចំណុចត្រូវពិនិត្យ*

១) ស្ថានភាពសំណង់នៃអាងគឺល្អ

ពិនិត្យមើលស្នាមប្រេះនៅលើសំណង់និងការលេចជ្រាបដោយសារការបាក់បែកឬភាពចាស់នៃបំពង់ឬវ៉ាន ឬតំណភ្ជាប់មិនបានល្អ។

២) វិធានការសុវត្ថិភាពសម្រាប់ផ្នែកខាងលើនៃសំណង់និងការលើកឧបករណ៍ឡើង

ពិនិត្យមើលថាតើមានតំឡើងបង្កាន់ដៃដើម្បីការពារការធ្លាក់ចុះដែរឬទេ។

- បណ្តាញចែកចាយទឹកស្អាត

*ចំណុចត្រូវពិនិត្យ*

១) ស្ថានភាពបំពង់និងវ៉ានគឺល្អ

ពិនិត្យមើលការលេចធ្លាយដោយសារការបែកបាក់ឬភាពចាស់នៃបំពង់ឬវ៉ាន ឬតំណភ្ជាប់មិនបានល្អ។

២) ទម្របំពង់

បើសិនមិនមានទម្របំពង់ទេ រំញ័រនិងកត្តាផ្សេងៗអាចធ្វើឱ្យបំពង់និងផ្នែកដទៃទៀតខូចបាន។

៣) វ៉ាននៅលើបំពង់បញ្ចេញទឹក

ត្រូវតំឡើងវ៉ានបញ្ចេញទឹកដើម្បីអាចបញ្ឈប់ទឹកនិងរៀបចំការកែសម្រួលលំហូរ នៅពេលជួសជុល។

## ៣.៩. ការតាមដានគុណភាពទឹកស្អាត

ប្រតិបត្តិករ ត្រូវមានឧបករណ៍ពិនិត្យគុណភាពទឹកចាំបាច់ ដើម្បីគ្រប់គ្រងគុណភាពទឹក ដូច្នេះទឹកស្អាតនឹងអនុលោមតាមស្តង់ដារគុណភាពទឹកស្អាតថ្នាក់ជាតិ។

## ៤. ការផ្តល់អនុសាសន៍លើលក្ខណៈបច្ចេកទេស

### ៤.១. ការបរាជ័យលើការផ្គុំកករ

| ករណី | មូលហេតុ | វិធានការ |
|---|---|---|
| ១. ភាពល្អក់និងកករទាប (ពណ៌ទឹកផៅ) | សារធាតុចាប់កករតិច (បញ្ហាការកំណត់ ការស្ទះបំពង់ សមត្ថភាពមានកំរិត) | ១. ពិនិត្យឧបករណ៍ [*1]<br>២. បង្កើនសារធាតុចាប់កករ<br>៣. កាត់បន្ថយបរិមាណទឹកផៅ |
| ២. ភាពល្អក់និងកករទាប (ពណ៌ស) | (បន្ទាប់ពីលាយសារធាតុគីមី) pH ទាប ឬ អាល់កាឡាំងទាប | ១. ពិនិត្យឧបករណ៍<br>២. បង្កើនសារធាតុអាល់កាឡាំង |
| | (បន្ទាប់ពីលាយសារធាតុគីមី) pH ខ្ពស់ និង អាល់កាឡាំងខ្ពស់ | ១. ពិនិត្យឧបករណ៍<br>២. បន្ថយសារធាតុអាល់កាឡាំង |
| | (បន្ទាប់ពីលាយសារធាតុគីមី) pH ខ្ពស់ | ១. ពិនិត្យឧបករណ៍<br>២. បង្កើនសារធាតុអាស៊ីត (ឬបង្កើនសារធាតុចាប់កករ) |
| ៣. កករតូចនិងរងមិនល្អ | pHទាបបន្តិច ឬ អាល់កាឡាំងទាបបន្តិច | ១. ពិនិត្យឧបករណ៍<br>២. បង្កើនសារធាតុអាល់កាឡាំង |
| | (បន្ទាប់ពីលាយសារធាតុគីមី) pHខ្ពស់បន្តិច និង អាល់កាឡាំងខ្ពស់បន្តិច | ១. ពិនិត្យឧបករណ៍<br>២. បង្កើនសារធាតុអាស៊ីត (ឬបង្កើនសារធាតុចាប់កករ) |
| | ទឹកផៅមានភាគល្អិតហ្មត់ច្រើន | បង្កើនសារធាតុចាប់កករ |
| | កំលាំងកូរបញ្ចូលគ្នាខ្លាំងឬខ្សោយ | ១. ពិនិត្យឧបករណ៍ |

[*1] វាគឺដើម្បីពិនិត្យពីភាពមិនប្រក្រតីនៃរូបសណ្ឋាន ដំណើរការ ឬការខូច

[*2] ករណីកកររីកធំទៅៗ៖ អាំងតង់ស៊ីតេលាយគឺខ្សោយ

ករណីកករមិនរីកធំ៖ អាំងតង់ស៊ីតេលាយគឺខ្លាំង

| | | |
|---|---|---|
| | | ២. ធ្វើចារតេស្ត[*2]<br>៣. កែសម្រួលកំលាំងកូរ |
| | សីតុណ្ហភាពទឹកទាប | បង្កើនសារធាតុចាប់កករ |
| ៤. កករធំ តែហើម និងងាយបែក | សារធាតុចាប់កករលើសកំរិត | ១. ពិនិត្យឧបករណ៍<br>២. កាត់បន្ថយសារធាតុចាប់កករ |
| ៥. ទំហំកករមិនដូចគ្នា | បរិមាណអស្ថេរភាពនៃការបន្តក់សារធាតុចាប់កករ | ពិនិត្យនិងកែតម្រូវឧបករណ៍ |
| | លំហូរផ្លូវកាត់នៅក្នុងអាងលាយ | កែលម្អសំណង់អាងលាយ |
| | ការកូរមិនស្ថេរភាព | ពិនិត្យនិងកែតម្រូវឧបករណ៍ |

## ៤.២. ការបរាជ័យលើការរងកករ

| ករណី | មូលហេតុ | វិធានការ |
|---|---|---|
| ១. ភាពល្អក់ដូចទៅនឹងទឹកឆៅ | ការដាក់សារធាតុចាប់កករតិច (បញ្ហាការកំណត់ ការស្ទះបំពង់ សមត្ថភាពមានកំរិត) | ១. ពិនិត្យឧបករណ៍<br>២. បង្កើនសារធាតុចាប់កករ<br>៣. កាត់បន្ថយបរិមាណទឹកឆៅ |
| ២. អាងរងមានពណ៌សដូចពពក | មិនបានសម្រួលតម្លៃpH ឬអាល់កាឡាំង | សូមពិនិត្យមើល ៤.១.២. |
| ៣. មានកករតូចៗច្រើននិងការរងមិនល្អ | - មិនបានសម្រួលតម្លៃpH ឬអាល់កាឡាំង<br>- ដាក់សារធាតុចាប់កករតិចនៅពេលគុណភាពទឹកប្រែប្រួល<br>- កំលាំងកូរមិនសមស្រប | សូមពិនិត្យមើល ៤.១.៣. |
| ៤. កករធំតែមិនសូវច្បាស់ | ការកើតឡើងនៃកករដែលហើមនិងងាយនឹងបែក | សូមពិនិត្យមើល ៤.១.៤. |

[*2] ករណីកកររីកធំទៅៗ៖ អាំងតង់ស៊ីតេលាយគឺខ្សោយ
ករណីកករមិនរីកធំ៖ អាំងតង់ស៊ីតេលាយគឺខ្លាំង

| | | |
|---|---|---|
| | ដោយសារការដាក់សារធាតុចាប់កករច្រើនពេក | |
| | ភាពមិនស្មើគ្នាដោយសារលក្ខខណ្ឌនៃការចាប់កករមិនស្មើគ្នា | សូមពិនិត្យមើល ៤.១.៥. |
| ៥. កករហូរឆ្លងនៅអាងបន្ទាប់ | លំហូរផ្លូវកាត់នៅក្នុងអាងរង (ពិសេសនៅបន្ទះពង្រង) | ១. តំឡើងឬកែលម្អជញ្ជាំងខណ្ឌ<br>២. កែលម្អផ្នែកហូរចូល |
| | ការកើនឡើងនៃកករឬការរាំងស្ទះបន្ទះពង្រង | លាងសំអាតបន្ទះពង្រង |
| | Surface loading លើស | តំឡើងឬបង្កើនបន្ទះពង្រង |
| | ភក់កើនឡើងខ្លាំង | កែលម្អប្រព័ន្ធនាំភក់ចេញ |

## ៤.៣. ការបរាជ័យលើការច្រោះ

១) អំពីការលាងអាង

ការលាងអាងច្រោះ ត្រូវធ្វើឡើងដោយការបញ្ចូលគ្នារវាងការលាងដោយប្រើទឹកនិងការលាងផ្ទៃខាងលើឬការលាងដោយប្រើខ្យល់។ ការលាងដោយប្រើទឹកតែឯង គឺមិនគ្រប់គ្រាន់ទេ ហើយដុំភក់អាចនឹងកើតមានឡើង។ ដុំភក់ គឺជាភក់ដែលមានរាងមូលដូចបាល់ដែលកើតមានឡើងនៅជុំវិញរវាងគ្រាប់ខ្សាច់និងគ្រាប់ក្រួស។ ដុំភក់អាចបង្កឱ្យមានពំនូកឬស្រទាប់ច្រោះប៉ោង។

វាមានសារៈសំខាន់ក្នុងការកំណត់បរិមាណទឹក សំពាធទឹក និងពេលវេលាសម្រាប់ការលាងសម្អាតដើម្បីឱ្យការលាងមានប្រសិទ្ធភាព។ អត្រាពង្រីកសមស្របនៃស្រទាប់ច្រោះនៅអំឡុងពេលលាងសម្អាតគឺ ២០-៣០%។

២) ការដោះស្រាយបញ្ហាចំបង

| ករណី | មូលហេតុ | វិធានការ |
| --- | --- | --- |
| ១. ភាពល្អក់ក្នុងអាងច្រោះកើនឡើងជាបណ្ដោះអាសន្ន ហើយក៏វងទៅវិញ | ការលេចឡើងនៃកករដំបូងបន្ទាប់ពីបានលាងអាង | ១. កាត់បន្ថយកម្រិតលំហូរបន្តិចម្ដងៗដើម្បីបញ្ចប់ការលាងអាង<br>២. បង្កើនកម្រិតលំហូរបន្តិចម្ដងៗនិងចាប់ដំណើរការច្រោះ<br>៣. ការបង្ហូរចេញនៃទឹកគ្រាដំបូងនៅពេលចាប់ផ្ដើមច្រោះ |
| ២. ភាពល្អក់នៅក្នុងច្រោះមានទំនោរកើនឡើងជាងពីមុន | ការកើនឡើងនៃភាពល្អក់បន្ទាប់ពីអាងវងដោយសារវត្តមាននៃស្លែ (ការប្រែប្រួលគុណភាពទឹកឆៅ) | ១. បង្កើនសារធាតុចាប់កករ<br>២. បន្ថក់សារធាតុចាប់កករមុនពេលអាងច្រោះ |
| | ការលាងមិនបានគ្រប់គ្រាន់ | ១. ពិនិត្យនិងកែសម្រួលឧបករណ៍<br>២. បង្កើនកំលាំងក្នុងការលាង |
| | ការថយចុះនៃខ្សាច់នៅក្នុងអាងច្រោះ ភាពមិនស្មើគ្នា ការបំពុលស្រទាប់ខ្សាច់និងក្រួស | បំពេញនិងបង្កើតខ្សាច់ក្នុងអាងច្រោះឡើងវិញ |
| ៣. ការលិចផ្ទៃខាងលើនៃស្រទាប់ច្រោះ | ការខូចប្រព័ន្ធបង្ហូរទឹកនៅខាងក្រោម ដែលធ្វើឱ្យស្រទាប់ច្រោះជ្រាបចូលទៅក្នុងអាងប្រមូលទឹក | ពិនិត្យនិងជួសជុលអាងប្រមូលទឹក |
| ៤. ការកើតមានឡើងនូវដុំកក់ស្នាមប្រេះនៅលើផ្ទៃខាងលើឬគំលាតរវាងស្រទាប់ច្រោះនិងជញ្ជាំង | ប្រសិទ្ធភាពនៃការលាងមិនគ្រប់គ្រាន់ហើយមានភាពល្អក់សំណល់នៅក្នុងស្រទាប់ច្រោះ | |

## ៥. ការសិក្សា

| | អាក្រក់ | ល្អ |
|---|---|---|
| ១ | ម៉ាស៊ីនបូមមិនបានចាប់ជាមួយនឹងប៊ូឡុង។ ភាពនឹងមិនគ្រប់គ្រាន់ នឹងបង្កឱ្យមានភាពរំញ័រ។  | ម៉ាស៊ីនបូមត្រូវបានចាប់ជាមួយនឹងប៊ូឡុង។  |
| ២ | ផ្នែកបង្វិលមិនត្រូវបានការពារដោយគម្រប។ ការតម្រឹមអ័ក្សមិនបានល្អ។  | ផ្នែកបង្វិលត្រូវបានការពារដោយគម្រប។  |
| ៣ | ការប្រើប្រាស់ទឹកឆៅដើម្បីលាយជាមួយសារធាតុគីមី។ ដោយសារទឹកឆៅមានប្រតិកម្មជាមួយនឹងសារធាតុគីមីនៅក្នុងធុងលាយ ប្រសិទ្ធភាពនៃការចាក់បញ្ចូលសារធាតុគីមីគឺខ្សោយ។  | |
| ៤ | មិនបានប្រើប្រាស់ធុងបន្តក់។ កម្រិតនៃការបន្តក់អាស្រ័យលើបរិមាណសារធាតុគីមីនៅក្នុងធុង។ | ការប្រើប្រាស់ធុងបន្តក់ឬម៉ូទ័របន្តក់ដើម្បីធ្វើឱ្យកម្រិតនៃការបន្តក់មានស្ថេរភាព។ |

| | អាក្រក់ | ល្អ |
|---|---|---|
| |  |  |
| | អាក្រក់ | ល្អ |
| ៥ | កំហាប់នៃសារធាតុគីមីដែលរលាយគឺមិនមានស្ថេរភាព។ | វាងាយស្រួលក្នុងការប្តូរកម្រិតនៃការបន្តក់។ |
| |  |  |
| ៦ | អាងរងមានភាពល្អក់។ ពិនិត្យស្ថានភាពនៃកករនិងកម្រិតនៃការដាក់សារធាតុចាប់កករ។ | |
| |  |  |
| ៧ | ដោយបរិមាណនៃទឹកតិច មិនមានទឹកនៅក្នុងអាងច្រោះទាំងមូល។ | កែសម្រួលចំនួនអាងច្រោះដែលធ្វើប្រតិបត្តិការហើយរក្សាទឹកនៅក្នុងវាលើកលែងតែអាងដែលមិនធ្វើសេវាកម្មសម្រាប់រយៈពេលណាមួយ។ |





៨ ក្លរចុងក្រោយ ត្រូវបានបន្តក់ចូលទៅក្នុងអាងស្តុកទឹកស្អាតជាមួយនឹងលំហូរឃើត។

ក្លរចុងក្រោយ ត្រូវបានបន្តក់ចូលទៅក្នុងបំពង់ក្រោយពីអាងច្រោះដោយប្រើប្រាស់ម៉ូទ័រ។





<u>អាក្រក់</u>

<u>ល្អ</u>

៩ អាងស្តុកទឹកស្អាតគឺមិនមានគម្របនិងបើកចំហរ។



អាងស្តុកទឹកស្អាតត្រូវមានគម្របដើម្បីការពារការបំពុលពីប្រភពខាងក្រៅដូចជាទឹកភ្លៀង ធូលី ជាដើម និងដើម្បីការពារការដុះស្លែដោយសារការត្រូវកំដៅថ្ងៃ។

| | | |
|---|---|---|
| ១០ | បំពង់មានសភាពរញ៉េរញ៉ៃ។  | បំពង់គួរត្រូវបានបង្រួមចូលគ្នាតាមដែលអាចធ្វើទៅបានដើម្បីការការពារការប្រើប្រាស់ខុស។ វាគួរតែមានបង្ហាញនូវឈ្មោះនៃសារធាតុរាវនិងទិសដៅរបស់វានៅលើបំពង់ដើម្បីងាយស្រួលក្នុងការចែកឱ្យដាច់ពីគ្នា។ |

## ៦. ឧបសម្ព័ន្ធ

| | | |
|---|---|---|
| ៦.១. ឧបសម្ព័ន្ធទី១ | ៖ | កំណត់ត្រាអធិការកិច្ច |
| ៦.២. ឧបសម្ព័ន្ធទី២ | ៖ | តារាង Checklist នៃការចុះអធិការកិច្ចផ្នែកបច្ចេកទេសលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត |
| ៦.៣. ឧបសម្ព័ន្ធទី៣ | ៖ | រូបភាពសកម្មភាពចុះអធិការកិច្ច និងប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត |
| ៦.៤. ឧបសម្ព័ន្ធទី៤ | ៖ | កម្រងសំនួរបឋមអំពីរបាយការណ៍បច្ចេកទេស និងអាជីវកម្មរបស់ប្រតិបត្តិករ |